# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ ១៦៧/០៧ គ.ជ.ប

**គោរពជូន**

**ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

**កម្មវត្ថុ** : ស្តីពីក្រុមអ្នកសង្កេតការណ៍នៃសាធារណរដ្ឋកូរ៉េ ស្នើសុំចូលរួមសង្កេតការណ៍ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ឆ្នាំ២០០៧ នៅកម្ពុជា ។

**យោង** : -លិខិតលេខ០៨៣.០៧.សកស ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៧ របស់ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំសាធារណរដ្ឋកូរ៉េ ។

-កំណត់ទូតលេខ OAD-1679 ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៧ របស់ក្រសួងការបរទេស និងពាណិជ្ជកម្ម នៃសាធារណរដ្ឋកូរ៉េ ។

តបតាមកម្មវត្ថុ និងយោងខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មានកិត្តិយស សូមជំរាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិជ្រាបថា ការសុំចូលរួមសង្កេតការណ៍ ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅកម្ពុជាដែលប្រព្រឹត្តទៅនាថ្ងៃទី០១ ខែ មេសា ឆ្នាំ២០០៧ របស់ក្រុមអ្នកសង្កេត ការណ៍នៃសាធារណរដ្ឋកូរ៉េនោះត្រូវអនុវត្តដូចខាងក្រោម:

-ចំពោះចំនួនក្រុមអ្នកសង្កេតការណ៍ដែលត្រូវចូលរួម អាស្រ័យទៅតាមតំរូវការរបស់ភាគីកូរ៉េ ។

-ចំពោះរបៀបចូលរួមសង្កេតការណ៍ ស្ថានទូតកូរ៉េប្រចាំកម្ពុជា ត្រូវមកទំនាក់ទំនងជាមួយ គ.ជ.ប (ការិយាល័យទំនាក់ទំនងគណបក្ស និងទទួលស្គាល់អ្នកសង្កេតការណ៍) ដើម្បីទទួលយកពាក្យស្នើសុំ ដោយភ្ជាប់មកជាមួយបញ្ជីរាយនាមអ្នកចូលរួមសង្កេតការណ៍ ដោយមានហត្ថលេខា និងត្រារបស់អគ្គរដ្ឋទូត ក្នុងនោះត្រូវបញ្ជាក់អំពីឈ្មោះ ភេទ អាយុ និងមុខងាររបស់អ្នកសង្កេតការណ៍ម្នាក់ៗផងដែរ ។

-ចំពោះរយៈពេលស្នាក់នៅកម្ពុជា អាស្រ័យទៅតាមតំរូវការរបស់ភាគីកូរ៉េ

-ចំពោះការស្នាក់នៅ មធ្យោបាយដឹកជញ្ជូន និងមធ្យោបាយផ្សេងៗទៀតជាបន្ទុករបស់ភាគីកូរ៉េ ។

-ពត៌មានផ្សេងៗទាក់ទងនឹងការបោះឆ្នោតអាចបើក Website របស់ គ.ជ.ប WWW.necelect.org.kh

អាស្រ័យសេចក្តីដូចបានជំរាបខាងលើ សូមឯកឧត្តម មេត្តាជ្រាបតាមការគួរ ។

សូមឯកឧត្តម ទទួលនូវការគោរពរាប់អាន ដ៏ខ្ពង់ខ្ពស់អំពីខ្ញុំ ។

ភ្នំពេញ, ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៧

ជ. គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ប្រធាន

អ៊ឹម សួស្តី

ចម្លងជូន

-ទីស្តីការគណៈរដ្ឋមន្ត្រី

-ក្រសួងមហាផ្ទៃ

-ស្ថានទូតកូរ៉េប្រចាំនៅកម្ពុជា

"ដើម្បីជូនជ្រាប"